# ការរក្សាការពារ ក្នុងរឿងក្ដីរដ្ឋប្បវេណី ផ្នែក 2

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ2018
ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

# ការសម្រេចសេចក្តី
# អំពី
# ការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី



# ការសម្រេចសេចក្ដីអំពីការក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្ដោះអាសន្ន

（1） តុលាការដែលមានសមត្ថកិច្ច(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា540)

- តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី（តុលាការនៃការជំនុំជម្រះលើកទី1 ។ ប៉ុន្តែបើអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។）

ឬ

- សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលត្រូវរឹបអូសជាបណ្ដោះអាសន្ន

  ទីតាំងទីស្នាក់ការរបស់ធនាគារ ឬ ទីតាំងដែលចលនវត្ថុស្ថិតនៅជាដើម

※ ចុះប្រសិនបើពាក្យសុំត្រូវបានដាក់ទៅតុលាការដែលគ្មានសមត្ថកិច្ចវិញ？

→ណែនាំឲ្យដកពាក្យសុំ ហើយឲ្យកែតម្រូវទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

（1） តុលាការដែលមានសមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា540)

- អំពី "តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី"

① មុនការដាក់ពាក្យបណ្តឹងអង្គសេចក្តី
សាលាដំបូងដែលមានសមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា7 តទៅ) លើអង្គសេចក្តី (អាចមានច្រើន)

② ក្រោយការដាក់ពាក្យបណ្តឹងអង្គសេចក្តី
សាលាដំបូងដែលកំពុងធ្វើការសម្រេចសេចក្តីលើបណ្តឹងអង្គសេចក្តី (បើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។)

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(2) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541)

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់(ក)
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ(ខ)
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ(គ)
- ភាពចាំបាច់នៃការរក្សាការពារ(ឃ)

※ អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ គប្បីសរសេរឲ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗ ដែលត្រូវបញ្ជាក់។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី2)

# ការសម្រេចសេចក្តីអំពីការក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

ដោយសារតែជានីតិវិធីនៃដីកាសម្រេច ដូច្នេះ មិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា539 មាត្រា114 កថា.ទី1 វាក្យ.ទី2 និង កថា.ទី2)

⇒តុលាការពិចារណាលើឯកសារដែលម្ចាស់បំណុលបានដាក់ ហើយសម្រេចថាតើបានបំពេញលក្ខខណ្ឌហើយ ឬនៅ។ ជាទូទៅ នៅក្នុងដំណាក់កាលនេះ តុលាការមិនជូនដំណឹងទៅកូនបំណុល ឬ ស្តាប់ការលើកឡើងរបស់កូនបំណុលជាអាទិ៍ទេ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

- តើបានរៀបចំលក្ខខណ្ឌបណ្តឹងហើយឬនៅ ?
- តើបានសរសេរអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំទេ ?
- តើមានសេចក្តីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារឬទេ ?
- តើមានសេចក្តីបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារឬទេ ?

※សេចក្តីបញ្ជាក់ដំបូង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា131)
ប្រសិនបើធ្វើការប្រៀបធៀបជាមួយការបញ្ជាក់ តុលាការអាចទទួលស្គាល់នូវអង្គហេតុដោយផ្អែកលើកម្រិតទាបជាងការបញ្ជាក់បាន ប៉ុន្តែ ការពិនិត្យលើភស្តុតាងនោះចាំបាច់ត្រូវតែជាភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តីអំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ

- ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា545 កថា.ទី1)
- ទោះបីជាសិទ្ធិលើបំណុលដែលភ្ជាប់នឹងលក្ខខណ្ឌ ឬ ពេលកំណត់ក៏បានដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា545 កថា.ទី2)
- ត្រូវមានការអះអាង និង សេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុនៃការកើតឡើងលម្អិត
- ក្នុងករណីដែលអាចព្យាករណ៍បានច្បាស់លាស់ថានឹងមានការតវ៉ា (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាដើម ) ចាំបាច់ត្រូវតែមានការឆ្លើយតបចំពោះការតវ៉ានោះ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

អំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ

➢ដើម្បីអាចធ្វើការបែងចែកជាមួយនឹងសិទ្ធិទាមទារដទៃទៀតបាន មានភាពចាំបាច់ក្នុងការកំណត់ ដោយប្រើប្រាស់មូលហេតុនៃការកើតឡើង ប្រភេទ និង ចំនួនទឹកប្រាក់ជាដើម

⇒●ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះការទាមទារនូវចំនួនសិទ្ធិលើបំណុលមួយផ្នែក ត្រូវបញ្ជាក់ឲ្យច្បាស់អំពីទឹកប្រាក់នៃសិទ្ធិលើបំណុលសរុបទាំងអស់ និង ការទាមទារមួយផ្នែកដូចតទៅ "ប្រាក់ចំនួន........ដុល្លារនៃប្រាក់សរុបចំនួន........"។

●ក្នុងករណីដែលមានសិទ្ធិដែលនឹងត្រូវបានរក្សាការពារចាប់ពី2 ឡើងទៅ ត្រូវកំណត់អំពីចំនួនទឹកប្រាក់ដែលទាមទារចំពោះសិទ្ធិលើបំណុលនីមួយៗ ម្តងមួយៗ (ចំពោះសិទ្ធិលើបំណុល A ប្រាក់ចំនួន............ ដុល្លារ ចំពោះសិទ្ធិលើបំណុល B ប្រាក់ចំនួន......... ដុល្លារ  សរុបទាំងអស់ ប្រាក់ចំនួន..............។)។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តីអំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ【ឧទាហរណ៍អំពីការសរសេរ】

‟ប្រាក់ចំនួន1ម៉ឺនដុល្លារដែលម្ចាស់បំណុលបានប្រគល់ឲ្យកូនបំណុលខ្ចីនៅថ្ងៃទី1 ខែមករា ឆ្នាំ2017 ដោយកាលបរិច្ឆេទនៃការសងត្រូវនឹងថ្ងៃទី31 ខែធ្នូ ឆ្នាំ 2017 ក្នុងអត្រាការប្រាក់10% ក្នុងមួយឆ្នាំ និង ប្រាក់ចំនួន1000ដុល្លារដែលជាការប្រាក់គិតចាប់ពីថ្ងៃទី 1ខែមករា ឆ្នាំ2017 រហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2017នៃអត្រាការប្រាក់នេះ សរុបទាំងអស់គឺប្រាក់ចំនួន11000 ដុល្លារ〞

‟សិទ្ធិលើបំណុលចំនួន1ម៉ឺនដុល្លារនៃប្រាក់ថ្លៃលក់ទិញពេជ្រ 1 គ្រាប់ដែលម្ចាស់បំណុលបានលក់ ហើយប្រគល់ឲ្យកូនបំណុលដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី1 ខែមករា ឆ្នាំ2017។〞

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូស

(3) ការសម្រេចសេចក្តី

អំពីកម្មវត្ថុ

- ត្រូវតែជាទ្រព្យសម្បត្តិរបស់កូនបំណុល។
- ចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់ ប្រសិនបើកម្មវត្ថុមានអ្វីផ្សេងក្រៅពីចលនវត្ថុ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា546)។ ជាពិសេសក្នុងករណីដែលកម្មវត្ថុជាសិទ្ធិលើបំណុល ចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់អំពីកម្រិតដែលកូនបំណុលទី៣អាចធ្វើការបែងចែកដោយងាយស្រួលរវាងកម្មវត្ថុ និង សិទ្ធិលើបំណុលផ្សេងទៀត។
- អត្ថិភាពនៃកម្មវត្ថុ មិនមែនជាកម្មវត្ថុនៃការសម្រេចសេចក្តីទេ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

（3） ការសម្រេចសេចក្តី
អំពីភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន
មានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាក
យ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា545 កថា.ទី1)

＝ ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន ប្រសិនបើមិនបានធ្វើការរឹបអូសជាបណ្តោះអាសន្នទុកនោះទេ នឹងមានការបារម្ភថា នៅពេលដែលទទួលបានលិខិតអនុវត្ត ទ្រព្យដែលនឹងត្រូវក្លាយជាកម្មវត្ថុអាចនឹងបាត់បង់ ហើយជាលទ្ធផលនឹងមិនអាចធ្វើការអនុវត្តដោយបង្ខំបាន។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្ដោះអាសន្ន

（3） ការសម្រេចសេចក្ដី

អំពីភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ន【ឧទាហរណ៍អំពីសេចក្ដីបញ្ជាក់ដំបូង】

① ស្ថានភាពនៃទ្រព្យសម្បត្តិរបស់កូនបំណុល (គ្មានទ្រព្យណាផ្សេងក្រៅពីកម្មវត្ថុ ហើយនៅត្រូវទទួលបន្ទុកកាតព្វកិច្ចដទៃទៀត ជាអាទិ៍)

⇒ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុអំពីលំនៅដ្ឋាន លិខិតឯកសារនៃសេចក្ដីបញ្ជាក់ដំបូងជាដើម

② ស្ថានភាពនៃអាជីវកម្ម (ស្ថានភាពនៃជំនឿទុកចិត្ត មុខរបរ)

⇒ការជូនដំណឹងអំពីការសរុបកាតព្វកិច្ច លិខិតរបាយការណ៍របស់ក្រុមហ៊ុនអធិការកិច្ច ឬ ការកត់ត្រាអំពីម្ចាស់បំណុលជាដើម

③ អង្គហេតុដែលទាក់ទងនឹងស្ថានភាពរបស់កូនបំណុល

⇒ លិខិតនៃសេចក្ដីថ្លែងការណ៍ លិខិតនៃរបាយការណ៍

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

（3） ការសម្រេចសេចក្តី

អំពីភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន【ចំណុចប្រុងប្រយ័ត្ន】

- ចំពោះចំនួននៃកម្មវត្ថុ (សិទ្ធិលើបំណុលជាដើម) ដែលអាចបែងចែកបាន មិនអាចអនុញ្ញាតឲ្យធ្វើការរឹបអូសជាបណ្តោះអាសន្ននូវផ្នែកដែលលើសពីចំនួននៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារទេ។

⇒នៅពេលដែលកម្មវត្ថុ គឺជាសិទ្ធិលើបំណុល ចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់អំពីចំនួនទឹកប្រាក់ដើម្បីកុំឲ្យលើសពីចំនួននៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារ។ ក្នុងករណីដែលយកសិទ្ធិលើបំណុលដែលមានចំនួនច្រើនមកធ្វើជាកម្មវត្ថុ ត្រូវបែងចែកនូវចំនួនសិទ្ធិដែលនឹងត្រូវបានរក្សាការពារនោះទៅតាមសិទ្ធិលើបំណុលនីមួយៗ ។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្ដោះអាសន្ន

（3） ការសម្រេចសេចក្ដី

អំពីភាពចាំបាច់នៃការរឹបអូសជាបណ្ដោះអាសន្ន【ការគិតនៅប្រទេសជប៉ុន】

- តាមដែលអាចធ្វើបាន គួរតែយកកម្មវត្ថុដែលធ្វើឲ្យជះឥទ្ធិពលតិចតួចដល់កូនបំណុល ជាធម្មតា ការជះឥទ្ធិពលដល់កូនបំណុលរួមមាន៖

  **<u>អចលនវត្ថុ ＜សិទ្ធិលើបំណុល ＜ចលនវត្ថុ</u>**

  ហើយ ទ្រព្យដែលប្រើប្រាស់សម្រាប់អាជីវកម្ម (ផលិតផលជាដើម ) នឹងមានឥទ្ធិពលធ្ងន់ធ្ងរដល់កូនបំណុលជាងទ្រព្យដទៃទៀត។

⇒គេគិតថា ប្រសិនបើកូនបំណុលមានអចលនវត្ថុដែលជាលំនៅដ្ឋាន គួរតែធ្វើការរឹបអូសជាបណ្ដោះអាសន្នលើលំនៅដ្ឋាននោះជាមុនសិន ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(4) ប្រាតិភោគ

- ក្នុងករណីដែលតុលាការឲ្យដាក់ប្រាតិភោគ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា542) ជាដំបូងត្រូវកំណត់អំពីចំនួននៃប្រាតិភោគ និង កំណត់ពេល ដោយដីកាសម្រេច។ ប្រសិនបើតុលាការបានបញ្ជាក់អំពីការដាក់ប្រាតិភោគរួចហើយ នឹងចេញដីកាសម្រេចរក្សាការពារ។
- អ្នកដាក់ប្រាតិភោគត្រូវតម្កល់ ឬ ផ្ញើប្រាក់ជាអាទិ៍នៅកន្លែងតម្កល់ (តុលាការ) (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា71 កថា.ទី1)។
- រហូតដល់កំណត់ពេល ប្រសិនបើប្រាតិភោគមិនត្រូវបានដាក់ទេ តុលាការនឹងលើកចោលពាក្យសុំ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

（4） ប្រាតិភោគ

- ប្រាតិភោគនៃការរក្សាការពារ គឺការធានានូវការខូចខាតដែលកូនបំណុលនឹងទទួលរង ដោយសារតែការអនុវត្តដីកាសម្រេចរក្សាការពារខុស។
- ចំនួននៃប្រាតិភោគ គឺកំណត់ដោយយកមូលដ្ឋានតាមតម្លៃរបស់កម្មវត្ថុដែលត្រូវរឹបអូស។ ក្នុងករណីអចលនវត្ថុដែលភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវកំណត់ដោយយកមូលដ្ឋានតាមចំនួនដែលបានដកចំនួនប្រាតិភោគចេញ
- ចំនួនប្រាតិភោគក៏មានភាពខុសគ្នាទៅតាមកម្មវត្ថុផងដែរ។ ជាធម្មតា បើកម្រិតដែលកូនបំណុលនឹងត្រូវទទួលរងឥទ្ធិពលកាន់តែធំនោះ ចំនួនប្រាតិភោគក៏កាន់តែច្រើនដែរ។
- នៅប្រទេសជប៉ុន ស្ទើរតែគ្មានការចេញដីកាសម្រេចណាដែលមិនបានបង្គាប់ឲ្យដាក់ប្រាតិភោគនោះទេ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

(5) ដីកាសម្រេច

- នៅពេលដែលធ្វើដីកាសម្រេច តុលាការត្រូវតែកំណត់អំពីប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា547 កថា.ទី1)។ កូនបំណុលអាចទទួលបានការលុបចោលនូវការអនុវត្តការរឹបអូសជាបណ្តោះអាសន្នបាន (ប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ននឹងត្រូវមកជំនួសឲ្យកម្មវត្ថុ។) ប្រសិនបើបានផ្ញើប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ។
- នៅប្រទេសជប៉ុនវិញ ភាគច្រើនតុលាការកំណត់អំពីចំនួនប្រាក់រំដោះពីការរឹបអូសជាបណ្តោះអាសន្ន ស្មើនឹងចំនួនសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារដែរ ប៉ុន្តែ ប្រសិនបើបានដឹងច្បាស់ថាតម្លៃនៃកម្មវត្ថុទាបជាងចំនួននៃសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារភាគច្រើន តុលាការកំណត់ឲ្យស្មើនឹងតម្លៃនៃកម្មវត្ថុនោះវិញ។

# ការសម្រេចសេចក្តីអំពីការក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

1. ការរឹបអូសជាបណ្តោះអាសន្ន

（5） ដីកាសម្រេច

• ប្រសិនបើចុងក្រោយ តុលាការមិនបានទទួលស្គាល់នូវការរឹបអូសជាបណ្តោះអាសន្នទេនោះ ?

⇒ត្រូវចេញដីកាសម្រេចលើកចោល ឬ ទាក់ទងទៅកាន់ម្ចាស់បំណុលឲ្យមកដកពាក្យសុំ។

※ រាល់ដីកាសម្រេចលើកចោលទាំងអស់ មិនចាំបាច់បញ្ជូនទៅកាន់កូនបំណុលទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា543) ។ ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលបានលើកចោលមួយផ្នែក ក៏មានផ្នែកដែលតុលាការបានទទួលស្គាល់ក្នុងនោះដែរ ដូច្នេះ ចាំបាច់ត្រូវតែបញ្ជូនឲ្យទៅកូនបំណុល។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(1) តុលាការដែលមានសមត្ថកិច្ច (ក្រមរដ្ឋប្បវេណី មាត្រា540)

- តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី (តុលាការនៃការជំនុំជម្រះលើកទី1 ។ ប៉ុន្តែ បើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។ )

ឬ

- សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុវិវាទ

※ ចុះប្រសិនបើពាក្យសុំត្រូវបានដាក់ទៅតុលាការដែលគ្មានសមត្ថកិច្ចវិញ?

→ណែនាំឲ្យដកពាក្យសុំ ហើយឲ្យកែតម្រូវទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（1） តុលាការដែលមានសមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា540)

• អំពី "តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី"

① មុនការដាក់ពាក្យបណ្តឹងអង្គសេចក្តី

សាលាដំបូងដែលមានសមត្ថកិច្ច (ចាប់ពីក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា7 តទៅ) លើអង្គសេចក្តី (អាចមានច្រើន)

② ក្រោយការដាក់ពាក្យបណ្តឹងអង្គសេចក្តី

សាលាដំបូងដែលកំពុងធ្វើការសម្រេចសេចក្តីលើបណ្តឹងអង្គសេចក្តី (បើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។)

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(2) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541)

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់(ក)
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ(ខ)
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ(គ)
- ភាពចាំបាច់នៃការរក្សាការពារ(ឃ)

※ អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ គប្បីសរសេរឲ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗ ដែលត្រូវបញ្ជាក់។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី2)

# ការសម្រេចសេចក្ដីអំពីការការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(3) ការសម្រេចសេចក្ដី

ដោយសារតែជានីតិវិធីនៃដីកាសម្រេច ដូច្នេះ មិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា539 មាត្រា114 កថា.ទី1 វាក្យ.ទី2 និង កថា.ទី2)

⇒តុលាការធ្វើការពិចារណាលើឯកសារដែលម្ចាស់បំណុលបានដាក់ ហើយធ្វើការសម្រេចថា តើបានបំពេញលក្ខខណ្ឌហើយ ឬនៅ។ ជាទូទៅ នៅក្នុងដំណាក់កាលនេះ តុលាការមិនជូនដំណឹងទៅកូនបំណុល ឬ ស្ដាប់ការលើកឡើងរបស់កូនបំណុលជាអាទិ៍ទេ។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（3） ការសម្រេចសេចក្ដី

- តើបានរៀបចំលក្ខខណ្ឌបណ្ដឹងហើយឬនៅ？
- តើបានសរសេរអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំទេ？
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារឬទេ？（ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី3）
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារឬទេ？（ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី3）

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(3) ការសម្រេចសេចក្តី

អំពីភាគីម្ខាងទៀតនៃការដាក់ពាក្យសុំ (កូនបំណុល)

គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទគឺ <u>កំណត់ភាគីបណ្តឹង</u>

⇒ ប្រសិនបើជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់គឺ នឹងត្រូវហាមឃាត់នូវការកែប្រែស្ថានភាពនៃអង្គហេតុដែលជាការកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយរក្សាការពារដើម្បីអនុវត្តដោយបង្ខំនៅពេលអនាគត។

⇒ កូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ គឺជាអ្នកដែលកាន់កាប់ដោយផ្ទាល់លើវត្ថុដែលជាកម្មវត្ថុនៃវិវាទ (អ្នកដែលកាន់កាប់ដោយផ្ទាល់ ឬអ្នកដែលជួយកាន់កាប់ ត្រូវតែមិនមែនជាកូនបំណុល)។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(3) ការសម្រេចសេចក្តី

អំពីភាគីម្ខាងទៀតនៃការដាក់ពាក្យសុំ(កូនបំណុល)

គោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទគឺ កំណត់ភាគីបណ្តឹង

⇒ ប្រសិនបើជាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងដែលបានយកសិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីមកធ្វើជាសិទ្ធិដែលត្រូវបានរក្សាការពារ គឺនឹងត្រូវហាមឃាត់កូនបំណុលកុំឲ្យលក់អចលនវត្ថុបន្តឲ្យទៅអ្នកដទៃ ហើយត្រូវចុះបញ្ជីអំពីគោលបំណងទាំងនេះចំពោះអចលនវត្ថុដែលនឹងត្រូវចាត់ចែងជាបណ្តោះអាសន្ន។

⇒ ក្នុងករណីដែលបានយកសិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីមកធ្វើជាសិទ្ធិដែលត្រូវបានរក្សាការពារនោះ កូនបំណុលនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុគឺ ជាបុគ្គលដែលបានចុះក្នុងបញ្ជីបច្ចុប្បន្ន។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(3) ការសម្រេចសេចក្តី

អំពីខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់មាន 3ប្រភេទ (យោងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា549)

- ការអនុញ្ញាតឲ្យកូនបំណុលបន្តប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ(ជាគោលការណ៍នៅប្រទេសជប៉ុន)

  ※ កូនបំណុល ត្រូវជាអ្នកជួយកាន់កាប់របស់អាជ្ញាសាលា។

- ដកហូតវត្ថុដែលជាកម្មវត្ថុនៃវិវាទពីកូនបំណុល ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រង
- ដកហូតវត្ថុដែលជាកម្មវត្ថុនៃវិវាទពីកូនបំណុល ហើយអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់

⇒ចាំបាច់ត្រូវបង្ហាញឲ្យបានច្បាស់ថា តើទាមទារនូវការចាត់ចែងជាបណ្តោះអាសន្នប្រភេទណា?

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（3） ការសម្រេចសេចក្ដី

អំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ

➢ សិទ្ធិដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់
—សិទ្ធិទាមទារឲ្យប្រគល់វត្ថុ ឬ រើចេញពីវត្ថុ

➢ សិទ្ធិដែលនឹងត្រូវបានរក្សាការពារនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង
—សិទ្ធិទាមទារឲ្យផ្ដល់តាវកាលិកចំពោះវត្ថុដែលបានកំណត់ជាក់លាក់ (ភាគច្រើន គឺសិទ្ធិទាមទារឲ្យចុះបញ្ជី)

➢ មិនចាំបាច់កំណត់ឲ្យបានច្បាស់លាស់ហើយលម្អិតជាងការរឹបអូសជាបណ្ដោះអាសន្នទេ ប៉ុន្តែ ចាំបាច់ត្រូវមានការអះអាង និង សេចក្ដីបញ្ជាក់ដំបូងអំពីមូលហេតុនៃការកើតឡើងលម្អិត

➢ សិទ្ធិលើបំណុលដែលភ្ជាប់លក្ខខណ្ឌ ឬ ពេលកំណត់ក៏បានដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រ548 កថា.ទី3 មាត្រា545 កថា.ទី2)

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（3） ការសម្រេចសេចក្ដី

អំពីភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្ន

មានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កថា.ទី1)

ឧទា) កូនបំណុលអាចនឹងផ្ទេរការកាន់កាប់ (ការចុះបញ្ជី) លើកម្មវត្ថុឲ្យទៅតតិយជនបាត់ ។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（3） ការសម្រេចសេចក្ដី

អំពីភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្ន【ចំណុចប្រុងប្រយ័ត្នអំពីការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់】

មានត្រឹមតែសេចក្ដីបញ្ជាក់ដំបូងដែលអាចបញ្ជាក់ថា "មានការបារម្ភថា កូនបំណុលនឹងធ្វើសកម្មភាពផ្ទេរការកាន់កាប់" ក្នុងករណីដែលអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទក៏បានដែរ។ ប៉ុន្តែករណីក្រៅពីនេះ ដោយសារតែនឹងធ្វើឲ្យកូនបំណុលទទួលរងឥទ្ធិពលធ្ងន់ធ្ងរ ដូច្នេះ ត្រូវមានសេចក្ដីបញ្ជាក់ដំបូងដែលបញ្ជាក់ថា គោលបំណងនៃការរក្សាការពារសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគតមិនអាចសម្រេចបានទេ បើគ្រាន់តែផ្អែកទៅលើអានុភាពនៃការកំណត់ភាគីតែប៉ុនហ្នឹង។ បន្ថែមពីនេះទៀត ក្នុងករណីដែលតុលាការអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ចាំបាច់ត្រូវមានសេចក្ដីបញ្ជាក់ដំបូងអំពីភាពត្រឹមត្រូវក្នុងការអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(4) ប្រាតិភោគ

- ក្នុងករណីឲ្យដាក់ប្រាតិភោគ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា542) ជាដំបូងត្រូវកំណត់អំពីចំនួននៃប្រាតិភោគ និង កំណត់ពេល ដោយដីកាសម្រេច។ ប្រសិនបើតុលាការបានបញ្ជាក់អំពីការដាក់ប្រាតិភោគរួចហើយ នឹងចេញដីកាសម្រេចរក្សាការពារ។
- អ្នកដាក់ប្រាតិភោគត្រូវតម្កល់ ឬ ផ្ញើប្រាក់ជាអាទិ៍នៅកន្លែងតម្កល់ (តុលាការ) (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា71 កថា.ទី 1 )។
- រហូតដល់កំណត់ពេល ប្រសិនបើប្រាតិភោគមិនបានដាក់ទេ តុលាការនឹងលើកចោលពាក្យសុំ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

（4） ប្រាតិភោគ

- ប្រាតិភោគនៃការរក្សាការពារ គឺការធានានូវការខូចខាតដែលកូនបំណុលនឹងទទួលរង ដោយសារតែការអនុវត្តដីកាសម្រេចរក្សាការពារខុស។
- ចំនួននៃប្រាតិភោគ គឺកំណត់ដោយយកមូលដ្ឋានតាមតម្លៃរបស់កម្មវត្ថុដែលត្រូវរឹបអូស។ នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ចំនួនប្រាតិភោគនឹងត្រូវកំណត់ដោយយកមូលដ្ឋានតាមចំនួនថ្លៃឈ្នួល។
- នៅប្រទេសជប៉ុន ស្ទើរតែគ្មានការចេញដីកាសម្រេចណាដែលមិនបានបង្គាប់ឲ្យដាក់ប្រាតិភោគនោះទេ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

2. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

(5) ដីកាសម្រេច

- ប្រសិនបើចុងក្រោយ តុលាការមិនបានទទួលស្គាល់នូវការរឹបអូសជាបណ្តោះអាសន្នទេនោះ ?

⇒តើត្រូវធ្វើដីកាសម្រេចលើកចោល ឬ ទាក់ទងទៅកាន់ម្ចាស់បំណុលឲ្យមកដកពាក្យសុំ ?

※ រាល់ដីកាសម្រេចលើកចោលទាំងអស់មិនចាំបាច់បញ្ជូនទៅកាន់កូនបំណុលទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា543) ។ ប៉ុន្តែ នៅក្នុងដីកាសម្រេចដែលបានលើកចោលមួយផ្នែក ក៏មានផ្នែកដែលតុលាការបានទទួលស្គាល់ក្នុងនោះដែរ ដូច្នេះ ចាំបាច់ត្រូវតែបញ្ជូនឲ្យទៅកូនបំណុល។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

3 . ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

（1） តុលាការដែលមានសមត្ថកិច្ច (ក្រមរដ្ឋប្បវេណី មាត្រា540)

- តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី (តុលាការនៃការជំនុំជម្រះលើកទី1 ។ ប៉ុន្តែ បើអង្គសេចក្ដី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។ )

ឬ

- សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ

  ទីកន្លែងនៃសំណង់ក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការសាងសង់

※ ចុះប្រសិនបើពាក្យសុំត្រូវបានដាក់ទៅតុលាការដែលគ្មានសមត្ថកិច្ចវិញ ?

→ណែនាំឲ្យដកពាក្យសុំ ហើយឲ្យកែតម្រូវទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3． ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

（1） តុលាការដែលមានសមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា540)

- អំពី "តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្តី"

① មុនការដាក់ពាក្យបណ្តឹងអង្គសេចក្តី

សាលាដំបូងដែលមានសមត្ថកិច្ច (ក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា7តទៅ) លើអង្គសេចក្តី (អាចមានច្រើន)

② ក្រោយការដាក់ពាក្យបណ្តឹងអង្គសេចក្តី

សាលាដំបូងដែលកំពុងធ្វើការសម្រេចសេចក្តីលើបណ្តឹងអង្គសេចក្តី (បើអង្គសេចក្តី ត្រូវបានចាត់ការក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ គឺតុលាការនៃការជំនុំជម្រះឧទ្ធរណ៍។)

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3 . ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(2) ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541)

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់(ក)
- ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ(ខ)
- សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ(គ)
- ភាពចាំបាច់នៃការរក្សាការពារ(ឃ)

※ អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់នៃការរក្សាការពារ គប្បីសរសេរឲ្យបានច្បាស់លាស់ និង សរសេរនូវភស្តុតាង តាមហេតុនីមួយៗ ដែលត្រូវបញ្ជាក់។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី2)

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន មិនអាចធ្វើឡើងបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កថា.ទី4)។

⇒ ផ្អែកតាមការកំណត់បែបនេះ តុលាការចាំបាច់ត្រូវកំណត់អំពីកាលបរិច្ឆេទនៃការសួរជាអាទិ៍ ហើយទាក់ទងទៅម្ចាស់បំណុល និង កូនបំណុល ព្រមទាំងត្រូវផ្ញើឯកសារថតចម្លងនៃលិខិតពាក្យសុំរក្សាការពារ និង ឯកសារសេចក្តីបញ្ជាក់ដំបូង ដើម្បីឲ្យកូនបំណុលរៀបចំការឆ្លើយតប ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

（3） ការសម្រេចសេចក្តី

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន មិនអាចធ្វើឡើងបានឡើយ បើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កថា.ទី4)។

ចុះក្នុងករណីដែលត្រូវលើកចោលវិញ?

⇒ ក្នុងករណីដែលមានភាពច្បាស់លាស់ថានឹងត្រូវលើកចោលគ្រប់ចំណុចទាំងអស់ ទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ក៏ដោយ ក៏អាចចេញដីកាសម្រេចលើកចោលគ្រប់ចំណុច ដោយមិនចាំបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់បានដែរ។ ក្នុងករណីបែបនោះ មិនចាំបាច់ផ្តល់ដំណឹងទៅកូនបំណុលទេ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

（3） ការសម្រេចសេចក្តី

ករណីដែលអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នដោយមិនបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ ដែលជា"ស្ថានភាពពិសេសដែលនាំឲ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឲ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ" (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កថា.ទី 4 វាក្យ.ទី2) ជាអ្វីទៅវិញ?

⇒ ករណីធ្វើឲ្យកូនបំណុលមានលទ្ធភាពខ្ពស់ក្នុងការគេចចេញពីការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដោយសារតែធ្វើការសួរកូនបំណុល ឬ ករណីដែលមិនអាចសម្រេចគោលបំណងនៃការចាត់ចែងជាបណ្តោះអាសន្នបាន ដោយសារតែការចាត់ចែងជាបណ្តោះអាសន្នមិនបានចេញឲ្យទាន់ថ្ងៃដែលបានកំណត់ ដោយសារតែការសួរកូនបំណុលនឹងធ្វើឲ្យថ្ងៃដែលបានកំណត់នោះមានលទ្ធភាពខ្ពស់ក្នុងការកន្លងផុត (លើកលែងករណីដែលអាចដាក់ពាក្យសុំបានឆាប់ជាងនេះ) ជាអាទិ៍

# ការសម្រេចសេចក្តីអំពីការក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

ករណីដែលអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នដោយមិនបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ដែលជា "ស្ថានភាពពិសេសដែលនាំឲ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឲ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងកាត់តាមកាលបរិច្ឆេទនោះ" (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 548 កថា.ទី4 វាក្យ.ទី2) ជាអ្វីទៅវិញ?

※ ការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្នដោយមិនបើកការទាញហេតុផលដោយផ្ទាល់មាត់ គឺជាករណីលើកលែង ហើយមិនអាចទទួលស្គាល់នូវ "ស្ថានភាពពិសេស" បានដោយងាយស្រួលទេ។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

(3) ការសម្រេចសេចក្ដី

- តើបានរៀបចំលក្ខខណ្ឌបណ្ដឹងហើយឬនៅ?
- តើបានសរសេរអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំទេ?
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារឬទេ? (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541កថា.ទី3)
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃការរក្សាការពារឬទេ? (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា541 កថា.ទី3)

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

អំពីខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន គឺជាការរក្សាការពារនៅក្នុងរឿងក្តីរដ្ឋប្បវេណីដែលមិនអាចធ្វើការកំណត់ឲ្យជាក់លាក់បានទេ ហើយមានភាពខុសគ្នាពីខ្លឹមសារនៃការចាត់ចែងជាបណ្តោះអាសន្នដែលម្ចាស់បំណុលបានទាមទារដោយផ្អែកលើគ្រោះថ្នាក់បន្ទាន់ដែលកំពុងជួបប្រទះជាក់ស្តែង និង សិទ្ធិដែលត្រូវបានរក្សាការពារជាអាទិ៍។

⇒ ដោយគិតអំពីការអនុវត្តរក្សាការពារផងដែរនោះ គួរតែបង្ហាញឲ្យបានច្បាស់ថា តើទាមទារអ្វីទៅកាន់ម្ចាស់បំណុលជាបណ្តោះអាសន្ន។ អាចទាមទារជាបណ្តោះអាសន្នអំពីការមិនឲ្យធ្វើសកម្មភាពក៏បានដែរ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(3) ការសម្រេចសេចក្តី

អំពីខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ បើនៅក្នុងអង្គសេចក្តីមិនអាចធ្វើការបង្គាប់បាន (ខ្លឹមសារដែលមិនអាចយកមកសរសេរនៅក្នុងសេចក្តីសម្រេចបញ្ចប់) ទោះបីជាអត្ថិភាពនៃសិទ្ធិដែលនឹងត្រូវបានរក្សាការពារអាចធ្វើការទទួលស្គាល់បានក៏ដោយ ក៏មិនអាចធ្វើការបង្គាប់ (សរសេរខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់) នៅក្នុងការរក្សាការពារបានដែរ។

**⇒ ចំណុចសំខាន់គឺ "អ្វីជាសិទ្ធិដែលនឹងត្រូវរក្សាការពារ?" "តើអាចធ្វើអ្វីបានខ្លះដោយផ្អែកលើសិទ្ធិនោះ?"**

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

(3) ការសម្រេចសេចក្ដី
អំពីសិទ្ធិដែលនឹងត្រូវបានរក្សាការពារ

- មិនមានការកំណត់អំពីខ្លឹមសារនៃសិទ្ធិលើបំណុលទេ។
- ដោយគិតអំពីការកោះហៅកូនបំណុលឲ្យមកធ្វើការឆ្លើយតបផងដែរនោះ គួរតែធ្វើការអះអាងឲ្យស្មើទៅនឹងកម្រិតនៃនីតិវិធីនៃអង្គសេចក្ដី។
- សេចក្ដីបញ្ជាក់ដំបូង គឺជាការគ្រប់គ្រាន់សម្រាប់ការបញ្ជាក់។
- សិទ្ធិលើបំណុលដែលភ្ជាប់លក្ខខណ្ឌ ឬ ពេលកំណត់ក៏បានដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រ548 កថា.ទី3 មាត្រា545 កថា.ទី2)

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

(3) ការសម្រេចសេចក្ដី

អំពីភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្ន

ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (ក្រមរដ្ឋប្បវេណី មាត្រា548 កថា.ទី2)

⇒ ▪ប្រសិនបើអាចចាំរហូតដល់មានសាលក្រមនៃអង្គសេចក្ដីបាន មានន័យថា មិនមានភាពចាំបាច់នោះទេ។

▪ប្រសិនបើធ្វើការពិចារណាដោយប្រៀបធៀបនូវការខាតបង់ផលប្រយោជន៍ដែលនឹងកើតឡើងចំពោះម្ចាស់បំណុលដោយសារតែការមិនបានបង្គាប់ឲ្យចាត់ចែងជាបណ្ដោះអាសន្ន ជាមួយនឹងការខាតបង់ផលប្រយោជន៍ដែលនឹងកើតឡើងចំពោះកូនបំណុលដោយសារតែការចាត់ចែងជាបណ្ដោះអាសន្ន ឃើញថាម្ចាស់បំណុលមានការខាតបង់ផលប្រយោជន៍ច្រើនជាង នោះមានន័យថា មានភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្ន។

# ការសម្រេចសេចក្ដីអំពីការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

（3－1） ការសួរ

ដើម្បីចេញនូវការបង្គាប់ឲ្យចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះបាន ជាគោលការណ៍ ចាំបាច់ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កឋា.ទី2)។ ជាទូទៅ ភាគច្រើនការសួរត្រូវបានធ្វើឡើងដោយវិធីងាយស្រួល។

ការសួរធ្វើឡើងជាអសាធារណៈក៏បានដែរ។ ជាទូទៅ តុលាការមិនត្រឹមតែកោះហៅកូនបំណុលប៉ុណ្ណោះទេ ថែមទាំងហៅម្ចាស់បំណុលផងដែរ ហើយធ្វើការសួររួមគ្នា។ វិធីនៃការសួរពុំមានការកំណត់ពិសេសណាមួយឡើយ ប៉ុន្តែ ជាទូទៅ ឲ្យគូភាគីដាក់ឯកសារលាយលក្ខណ៍អក្សរ ឬ ធ្វើឡើងដោយផ្ទាល់មាត់អំពីការអះអាងនៃសិទ្ធិដែលត្រូវបានរក្សាការពារ និង ភាពចាំបាច់ក្នុងការរក្សាការពារ ព្រមទាំងឲ្យដាក់ឯកសារនៃសេចក្ដីបញ្ជាក់ដំបូងទាំងនេះ ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

（3－1） ការសម្រេចសេចក្តី

- ការផ្សះផ្សាក៏អាចធ្វើនៅកាលបរិច្ឆេទនៃការសួរបានដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា539 មាត្រា97)។
- ខ្លឹមសារនៃការផ្សះផ្សាក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ ភាគច្រើនជាការផ្សះផ្សាដែលកំណត់អំពីវិធានការជាបណ្តោះអាសន្នរហូតដល់មានសាលក្រមអង្គសេចក្តី ប៉ុន្តែ ក៏អាចជាការផ្សះផ្សាចុងក្រោយដែលមានខ្លឹមសារបញ្ចប់វិវាទផងដែរ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(4) ប្រាតិភោគ

- ក្នុងករណីឲ្យដាក់ប្រាតិភោគ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា542) ជាដំបូងត្រូវកំណត់អំពីចំនួននៃប្រាតិភោគ និង កំណត់ពេល ដោយដីកាសម្រេច។ ប្រសិនបើតុលាការបានបញ្ជាក់អំពីការដាក់ប្រាតិភោគរួចហើយ នឹងចេញដីកាសម្រេចរក្សាការពារ។
- អ្នកដាក់ប្រាតិភោគត្រូវតម្កល់ ឬ ផ្ញើប្រាក់ជាអាទិ៍នៅកន្លែងតម្កល់ (តុលាការ) (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា71 កថា.ទី1 )។
- រហូតដល់កំណត់ពេល ប្រសិនបើប្រាតិភោគមិនបានដាក់ទេ តុលាការនឹងលើកចោលពាក្យសុំ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

（4） ប្រាតិភោគ

- ប្រាតិភោគនៃការរក្សាការពារ គឺការធានានូវការខូចខាតដែលកូនបំណុលនឹងទទួលរង ដោយសារតែការអនុវត្តដីកាសម្រេចរក្សាការពារខុស។
- នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ជាទូទៅ ដោយសារតែនឹងធ្វើឲ្យការខូចខាតផលប្រយោជន៍ដែលកូនបំណុលច្រើនតែទទួលរងធ្ងន់ធ្ងរ ដូច្នេះ ភាគច្រើនប្រាតិភោគនឹងត្រូវកំណត់ចំនួនច្រើន។ ប៉ុន្តែ ក្នុងការចាត់ចែងជាបណ្តោះអាសន្នដែលបង្គាប់ឲ្យបង់ប្រាក់ជាបណ្តោះអាសន្ន ដោយសារតែ តុលាការបានទទួលស្គាល់នូវភាពចាំបាច់នៃការរក្សាការពារ ដោយផ្អែកលើមូលហេតុដែលម្ចាស់បំណុលគ្មានធនធាន ហេតុនេះ ហើយតុលាការមិនបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគឡើយ។

# ការសម្រេចសេចក្តីអំពីការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

3. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

(5) ដីកាសម្រេច

- ប្រសិនបើចុងក្រោយ តុលាការមិនបានទទួលស្គាល់នូវការចាត់ចែងជាបណ្តោះអាសន្នទេនោះ ?

⇒តើត្រូវចេញដីកាសម្រេចលើកចោល ឬ ទាក់ទងទៅកាន់ម្ចាស់បំណុលឲ្យមកដកពាក្យសុំ ?

※ រាល់ដីកាសម្រេចលើកចោលទាំងអស់មិនចាំបាច់បញ្ជូនទៅកាន់កូនបំណុលទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា543) ប៉ុន្តែ ក្នុងករណីដែលបានកោះហៅកូនបំណុលមកសួរជាអាទិ៍ គួរតែជូនដំណឹងអំពីខ្លឹមសារនៃដីកាសម្រេចឲ្យកូនបំណុលបានដឹងផងដែរ។ ដូចគ្នានឹងករណីដែលបានដកពាក្យសុំដែរ។